# សិទ្ធិរបស់អ្នកក្នុងបណ្តុំច្បាប់សិទ្ធិមូលដ្ឋានរបស់អ្នកជម្ងឺព្យាបាលនៅផ្ទះនៃរដ្ឋសហព័ន្ធ និងរដ្ឋ Minnesota

## មុនពេលអានឯកសារនេះ អ្នកគួរដឹង៖

ក្នុងឯកសារនេះ ពាក្យ "អ្នក" រួមទាំងខ្លួនអ្នកផ្ទាល់ អ្នកតំណាងរបស់អ្នក និងអ្នកដែលត្រូវចាត់តាំងតាមច្បាប់ផ្សេងទៀត តាមច្បាប់នៃរដ្ឋ Minnesota law ។ បើអ្នកស្នាក់នៅក្នុងមន្ទីរថែទាំងមនុស្សចាស់ បរិវេណថែទាំណាមួយ ឬមណ្ឌលថែទាំផ្សេងទៀត អ្នកត្រូវបានផ្តល់ឲ្យនូវសិទ្ធិទាំងនេះ ។ អ្នកក៏ត្រូវផ្តល់សិទ្ធិនេះដែរ បើអ្នកស្នាក់នៅក្នុងផ្តល់ការឧបត្ថម្ភដែលគ្រប់គ្រងសម្រាប់ការរស់នៅក្នុងមណ្ឌលដែលផ្អែកលើកកម្មវិធីសារធាតុគីមីដែលត្រូវអនុញ្ញាតដោយក្រសួង សេវាបម្រើពលរដ្ឋនៃរដ្ឋ Minnesota ។ គ្មានបុគ្គលិកមណ្ឌលណាម្នាក់ អាចតម្រូវឲ្យអ្នកបោះបង់សិទ្ធិនេះចោលជាថ្នូរនឹងលក្ខខណ្ឌចូលមកស្នាក់នៅក្នុងមណ្ឌល ឬបន្តស្នាក់នៅក្នុងមណ្ឌលនោះទេ ។

សិទ្ធិមួយចំនួនមានតែនៅក្នុងច្បាប់នៃរដ្ឋ Minnesota ប៉ុណ្ណោះ ។ សិទ្ធិទាំងនេះត្រូវបានបង្ហាញឡើងដោយអក្សរដិត ។ សិទ្ធិផ្សេងទៀតទាំងអស់ដែលមានក្នុងច្បាប់រដ្ឋសហព័ន្ធហើយត្រូវអនុវត្តចំពោះអ្នកស្នាក់នៅក្នុងមណ្ឌលដែលបានបញ្ជាក់ថានៅក្នុងកម្មវិធីធានារ៉ាប់រងសុខភាព និងសុវត្ថិភាពសង្គម ។ ប្រសិនបើសិទ្ធិរបស់អ្នកនៅក្នុងច្បាប់នៃរដ្ឋ Minnesota ប្រហាក់ប្រហែលនឹងសិទ្ធិរបស់អ្នកក្នុងច្បាប់រដ្ឋសហព័ន្ធ សិទ្ធិដែលមានក្នុងច្បាប់សហព័ន្ធមានអនុភាពជាង ។ ប៉ុន្តែការបន្ថែមអ្វីសំខាន់ៗផ្សេងទៀតក្នុងច្បាប់រដ្ឋ គឺត្រូវបង្ហាញដោយអក្សរដិត ។

បើអ្នកចង់បានឯកសារថតចម្លងដើម្បីបំពេញសិទ្ធិរបស់អ្នកក្នុងរដ្ឋ Minnesota មានឯកសារចម្លងនៅក្នុងមណ្ឌលរបស់អ្នក ។ បុគ្គលិកអាចប្រាប់អ្នកពីកន្លែងដែលអ្នកអាចរក ។

## គុណភាពជីវិត

មណ្ឌលត្រូវយកចិត្តទុកដាក់ចំពោះអ្នក ដែលលើកកម្ពស់ការរក្សា ឬការធ្វើឲ្យប្រសើរឡើងនៃគុណភាពជិវិតរបស់អ្នក ។

**1. សេចក្តីថ្លៃថ្នូរ** ។ មណ្ឌលត្រូវតែគួរសម និងយកចិត្តទុកដាក់ចំពោះអ្នកក្នុងលក្ខណៈ និងបរិយាកាសមួយដែលរក្សា និងធ្វើឲ្យប្រសើរឡើងនូវសេចក្តីថ្លៃថ្នូររបស់អ្នក និងត្រូវគោរពដោយទទួលស្គាល់យ៉ាងពេញលេញនូវបុគ្គលភាពរបស់អ្នក ។ **អ្នកមានសិទ្ធិទទួលបានការព្យាបាលឯកជន និងការថែទាំផ្ទាល់ខ្លួន (រួមទាំង ការពិភាក្សា ការប្រឹក្សាយោបល់ ការពិនិត្យ ការព្យាបាល និងសកម្មភាពអនាម័យផ្ទាល់ផ្សេងទៀតដូចជា ការចូលបង្គន់ ឬបន្ទប់ទឹក) លើកលែងតែជាតម្រូវការសម្រាប់សុវត្ថិភាព និងជំនួយការរបស់អ្នក ។**

**2. ការកំណត់ដោយខ្លួនឯង និងការចូលរួម** ។ អ្នកមានសិទ្ធិជ្រើសរើសនូវសកម្មភាពតារាងពេលវេលា និងការថែទាំសុខភាព រួមជាមួយសមាជិក សហគមន៍របស់អ្នក និងសម្រេចលើទិសដៅសម្រាប់ជីវិតរបស់អ្នកនៅក្នុងមណ្ឌលដែលចាំបាច់ណាស់សម្រាប់ខ្លួនអ្នក ។ **អ្នកមានសិទ្ធិចូលរួមក្នុងសកម្មភាពពាណិជ្ជកម្ម សាសនា នយោបាយ និងក្រុមសហគមន៍ រួមមានដូចជាការចូលរួមជាមួយមនុស្សដទៃទៀតក្នុងការបំពេញការងារដោយគ្មានការជ្រៀតជ្រែក ដើម្បីពង្រឹងការថែទាំរយៈពេលយូរអង្វែង បើសកម្មភាពនោះ មិនបំពានសិទ្ធិឯកជនរបស់អ្នកផ្សេង ។**

**3. ការចូលរួមក្នុងមន្ទីព្យាបាលមនុស្សចាស់ និងក្រុមគ្រួសារ ។** អ្នកមានសិទ្ធិរៀបចំ និងចូលរួមក្នុងក្រុមអ្នកស្នាក់នៅក្នុងមន្ទីរព្យាបាលមនុស្សចាស់នៅក្នុងមណ្ឌល។ គ្រួសាររបស់អ្នកមានសិទ្ធិជួបជាលក្ខណៈឯកជន នៅក្នុងមណ្ឌលជាមួយក្រុមគ្រួសារនៃអ្នកស្នាក់នៅក្នុងមន្ទីរព្យាបាលមនុស្សចាស់ផ្សេងទៀតបាន ។ នៅពេលដែលមានអ្នកស្នាក់នៅក្នុងមន្ទីរពេទ្យព្យាបាលមនុស្សចាស់ ឬក្រុមគ្រួសារ មណ្ឌលត្រូវស្តាប់ទស្សនៈ និងការតវ៉ា និងការណែនាំ របស់អ្នកស្នាក់នៅក្នុងមន្ទីរព្យាបាលមនុស្សចាស់ និងគ្រួសារ ដែលទាក់ទងនឹងសំណើគោលនយោបាយ និងសេចក្តីសម្រេចដែលប៉ះពាល់ដល់ការថែទាំអ្នកស្នាក់នៅក្នុងមន្ទីរព្យាបាលមនុស្សចាស់ និងការរស់នៅក្នុងមណ្ឌល ។ **អ្នកស្នាក់នៅ និងក្រុមប្រឹក្សាគ្រួសារត្រូវបានលើកទឹកចិត្ត ឲ្យផ្តល់អនុសាសន៍ទាក់ទងនឹងគោលនយោបាយមណ្ឌល** ។

**4. ការចូលរួមក្នុងសកម្មភាពផ្សេងៗទៀត** ។ អ្នកមានសិទ្ធិចូលរួមក្នុងសកម្មភាពសង្គម សាសនា និងសហគមន៍ដែលមិនរំខាន់ជាមួយសិទ្ធិរបស់អ្នកស្នាក់នៅក្នុងមន្ទីរព្យាបាលមនុស្សចាស់នៅក្នុងមណ្ឌលនេះ ។

**5. តម្រូវការនៃការស្នាក់អាស្រ័យ ។** អ្នកមានសិទ្ធិស្នាក់នៅ និងទទួលបានសេវាកម្មក្នុងមណ្ឌល ដោយការស្នាក់នៅដែលជាតម្រូវការរបស់អ្នក លើកលែងតែក្នុងករណីសុវត្ថិភាព ឬសុខភាព របស់អ្នក ឬអ្នកផ្សេងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ។

## ការថែទាំ និងការព្យាបាល

**6. ការថែទាំសុខភាពសមស្រប ។** អ្នកមានសិទ្ធិទទួលបានការថែទាំវេជ្ជសាស្ត្រ និងការថែទាំផ្ទាល់ខ្លួនដោយសមស្រប ស្របតាមតម្រូវការផ្ទាល់ខ្លួន ដែលរៀបចំឡើងដើម្បីអាចឲ្យអ្នកសម្រេចបានកម្រិតខ្ពស់បំផុតនៃដំណើរការផ្នែករាងកាយ និង ស្មារតី ប៉ុន្តែសិទ្ធិនេះត្រូវបានរិតបន្តឹង នៅកន្លែងដែល ធនធានសាធារណៈ ឬឯកជនមិនអាចផ្តល់សេវាកម្មនោះបាន ។

**7. ទំនាក់ទំនងជាមួយនឹងសេវាកម្មសុខភាពផ្សេងទៀង និងអ្នកផ្គត់ផ្គង់ ។ អ្នកមានសិទ្ធិទទួលបានសេវាកម្មពីអ្នកផ្តល់សេវាខាងក្រៅ និងមានសិទ្ធិទទួលបាននូវអត្តសញ្ញាណ អាសយដ្ឋាន និងការរៀបរាប់អំពីសេវាផ្សេងទៀងរបស់អ្នកផ្តល់សេវានោះ តាមការស្នើសុំ ។ អ្នកមានសិទ្ធិជាវ ឬជួលវត្ថុ ឬសេវាកម្ម ដែលមិនរាប់បញ្ចូលនូវកញ្ចប់សេវាកម្មដែលផ្តល់ឲ្យដោយអ្នកផ្គត់ផ្គង់តាមជម្រើសរបស់អ្នកលើកលែងតែត្រូវបានកំណត់ ដោយច្បាប់ផ្សេង ។**

**8. ការបន្តការថែទាំ ។ អ្នកមានសិទ្ធិទទួលបានការថែទាំដោយទៀងទាត់ និងបន្តបន្ទាប់ពីបុគ្គលិកដែលត្រូវបានចាត់តាំង ដែលជាគោលនយោបាយរបស់មណ្ឌល ។**

**9. ការពិនិត្យមើល របាយការណ៍ និងការទទួលស្គាល់ការថែទាំ ។** អ្នកមានសិទ្ធិពិនិត្យមើលរបាយការណ៍របស់អ្នក ក្នុងរយៈពេល 24 ម៉ោងក្រោយការស្នើសុំ ហើយតាមរយៈសំណើជាលាយលក្ខណ៍អក្សរ និងក្នុងរយៈពេល 2 ថ្ងៃនៃថ្ងៃធ្វើការ អ្នកមានសិទ្ធិជាវរូបថតចម្លងក្នុងអត្រាមិនលើសពីអត្រាស្តង់ដានៅក្នុងសមាគមន៍របស់អ្នក ។ អ្នកមានសិទ្ធិពេញលេញក្នុងការទទួលបានការជូនដំណឹងជាភាសាដែលអ្នកអាចយល់ដឹងបាន អំពីស្ថានភាពសុខភាពរបស់អ្នក ។

**10. ការណែនាំជាមុន ។** អ្នកមានសិទ្ធិទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរទាក់ទងនឹង ការណែនាំជាមុន **(បច្ចុប្បន្ន ត្រូវហៅថា ការណែនាំការថែទាំសុខភាពក្នុងរដ្ឋ Minnesota)** រួមទាំង គោលនយោបាយលាយលក្ខណ៍អក្សររបស់មណ្ឌល និងច្បាប់ជាធរមានរបស់រដ្ឋ

ហើយដើម្បីរៀបចំបង្កើតជាការណែនាំជាមុនមួយ ។ **អ្នកមានសិទ្ធិចាត់តាំងបុគ្គលដែលគ្មានការពាក់ព័ន្ធ មានឋានៈជាសាច់ញាតិរបស់អ្នក ឲ្យធ្វើសេចក្តីសម្រេចលើការថែទាំសុខភាព ។**

**11. គ្រូពេទ្យព្យាបាល ។** អ្នកមានសិទ្ធិជ្រើសរើសយកគ្រូពេទ្យសម្រាប់ព្យាបាលអ្នក ។ មណ្ឌលត្រូវផ្តល់ឲ្យអ្នកនូវឈ្មោះ លក្ខណៈពិសេស អាសយដ្ឋានមុខរបរ និងលេខទូរស័ព្ទរបស់គាត់ ។

**12. ព័ត៌មានអំពីការព្យាបាល ។** អ្នកមានសិទ្ធិត្រូវបានជូនដំណឹងជាមុន អំពីការថែទាំ និងការព្យាបាលរបស់អ្នក ។ **បន្ថែមពីនេះ គ្រូពេទ្យព្យាបាលរបស់អ្នកត្រូវតម្រូវឲ្យអ្នកបំពេញព័ត៌មានបច្ចុប្បន្នភាព ទាក់ទងនឹងរោគសញ្ញា ការព្យាបាល ការប្រែប្រួល គ្រោះថ្នាក់ និងជោគវាសនារបស់អ្នក ។ ព័ត៌មាននេះត្រូវសរសេរពាក្យពេចន៍ជាភាសា ដែលអ្នកអាចយល់បាន ។ គ្រួសាររបស់អ្នក ឬអ្នកតំណាងដែលជ្រើសតាំង ឬអ្នកទាំងពីរនេះ អាចអមដំណើរបាន ។ អ្នកមានសិទ្ធិបដិសេធព័ត៌មាននេះ ។ បើអ្នកឈឺចាប់ដោយសារជម្ងឺមហារីកដោះ អ្នកត្រូវផ្តល់ដំណឹងសព្វយ៉ាងអំពីការប្រែប្រួល ប្រសិទ្ធភាព នៃវិធីសាស្រ្តព្យាបាល និងហានិភ័យកើតមានជាមួយ ការប្រើប្រាស់វិធីសាស្រ្តនីមួយៗ ។**

**13. ការចូលរួមក្នុងផែនការព្យាបាល ។** អ្នកមានសិទ្ធិចូលរួមក្នុងការធ្វើផែនការព្យាបាល និងថែទាំ ។ **សិទ្ធិនេះរួមមានឱកាសក្នុងការពិភាក្សាការព្យាបាល ការផ្លាស់ប្តូរដោយបុគ្គលដែលផ្តល់ការថែទាំ ឱកាសក្នុងការលើកសំណើ និងចូលរួមក្នុងសិក្ខាសាលាស្តីពីការថែទាំជាផ្លូវការ និងសិទ្ធិបញ្ចូលសមាជិក គ្រួសារ ឬអ្នកតំណាងផ្សេងទៀត ឬទាំងពីរ ។ ក្នុងព្រឹត្តិការណ៍នេះ អ្នកមិនអាចបង្ហាញវត្តមានសមាជិកគ្រួសារ ឬអ្នកតំណាងផ្សេងទៀតដែលត្រូវជ្រើសរើស ដោយអ្នកដែលអ្នកបានបញ្ចូលក្នុងសិក្ខាសាលានោះទេ ។**

**បើអ្នកបាត់បង់ស្មារតី វង្វេង ឬមិនអាចទាក់ទងបាន នៅពេលអ្នកចូលក្នុងមណ្ឌល មណ្ឌលត្រូវខិតខំប្រឹងប្រែង ដើម្បីជូនដំណឹងដល់ សមាជិកគ្រួសារ ឬបុគ្គលដែលត្រូវចាត់តាំងសម្រាប់ការទំនាក់ទំនងសង្គ្រោះបន្ទាន់ដោយសមហេតុផល ហើយអនុញ្ញាតឲ្យបុគ្គលនោះចូលរួមក្នុងការរៀបចំផែនការព្យាបាលរបស់អ្នកដែលជាតម្រូវការកំណត់ដោយច្បាប់របស់រដ្ឋ ។**

**14. ការជូនដំណឹងអំពីការផ្លាស់ប្តូរលក្ខខណ្ឌរបស់អ្នក ។** មណ្ឌលត្រូវប្រឹក្សាជាមួយអ្នកភ្លាមៗ ខណៈមានគ្រោះថ្នាក់បង្ករបួសដល់អ្នកដែលធ្វើឲ្យមានការប្រែប្រួលខ្លាំងលើរាងកាយ ស្មារតី ឬស្ថានភាពទស្សនៈរបស់អ្នក ដែលតម្រូវឲ្យផ្លាស់ប្តូរវិធីព្យាបាល ចេញ ឬការសម្រេចប្តូរ ឬឲ្យ

អ្នកចេញពីមណ្ឌលព្យាបាល ។ មណ្ឌលក៏ត្រូវទាក់ទងគ្រូពេទ្យរបស់អ្នក អ្នកតំណាងផ្លូវច្បាប់ និងសមាជិកគ្រួសាររបស់អ្នក ។

**15. ការបដិសេធការព្យាបាល** ។ អ្នកមានសិទ្ធិបដិសេធចំពោះការព្យាបាល ។ **ប្រសិនបើអ្នកបដិសេធការព្យាបាល ថ្នាំ ឬការកម្រិតរបបអាហារអ្នកត្រូវជូនដំណឹង ដូចជាអំពីការព្យាបាល ឬលទ្ធផលផ្នែកចិត្តវិទ្យាអំពីការបដិសេធ ដោយត្រូវកត់ត្រា ទុកក្នុងរបាយការណ៍ព្យាបាលរបស់អ្នក ។**

**16. ការគ្រប់គ្រងថ្នាំដោយខ្លួនឯង**។ អ្នកមានសិទ្ធិគ្រប់គ្រងថ្នាំដោយខ្លួនឯង ប្រសិនបើក្រុមប្រឹក្សាវិន័យរបស់មណ្ឌលបានកំណត់ ថាការអនុវត្តន៍ដូចនេះ មានសុវត្ថិភាព។

## សិទ្ធិទូទៅ

អ្នកមានសិទ្ធិមានជីវិតថ្លៃថ្នូរ មានសិទ្ធិក្នុងការជ្រើសរើស និងសម្រេចដោយខ្លួនឯង និងសិទ្ធិធ្វើការទំនាក់ទំនងជាមួយបុគ្គលផ្សេង និងប្រើប្រាស់សេវាកម្មទាំងខាងក្នុង និងខាងក្រៅមណ្ឌល ។ មណ្ឌលត្រូវការពារ និងលើកតម្កើងសិទ្ធិរបស់អ្នក រួមមានសិទ្ធិ នីមួយៗដូចរៀបរាប់ខាងក្រោម ។ **អ្នកត្រូវបានប្រាប់ នៅពេលអ្នកចូលមកក្នុងមណ្ឌលថាអ្នកមានសិទ្ធិតាមផ្លូវច្បាប់សម្រាប់ការពារអ្នកដូចដែល បានរៀបរាប់ក្នុងសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរនេះ ។**

**17. ការអនុវត្តន៍សិទ្ធិ ។** អ្នកមានសិទ្ធិក្នុងការអនុវត្តន៍សិទ្ធិរបស់អ្នកជាអ្នកស្នាក់នៅក្នុងមន្ទីរព្យាបាលមនុស្សចាស់ និងជាប្រជាពលរដ្ឋនៃសហរដ្ឋអាមេរិក និងសិទ្ធិរួចផុតពីការជ្រៀតជ្រែក ការគម្រាមកំហែង ការរើសអើង ឬការសងសឹកពីការអនុវត្តន៍សិទ្ធិរបស់អ្នកនៅក្នុងមណ្ឌល ។ បើអ្នកត្រូវបានវិនិច្ឆ័យថាជាជនអសមត្ថភាព តាមច្បាប់របស់រដ្ឋ សិទ្ធិរបស់អ្នកនឹងត្រូវបានអនុវត្តដោយបុគ្គលដែលបានតែងតាំងស្របតាមច្បាប់រដ្ឋ ដើម្បីបំពេញកិច្ចការក្នុងនាមជាអ្នក។ ប្រសិនបើអ្នកមិនទាន់ត្រូវបានវិនិច្ឆ័យថាជាជនអសមត្ថភាព អ្នកតំណាងផ្លូវច្បាប់ដែលត្រូវបានចាត់តាំងក្រោមច្បាប់របស់រដ្ឋ អាចអនុវត្តសិទ្ធិរបស់អ្នកតាមការអនុវត្តន៍ដោយច្បាប់របស់រដ្ឋ ។

**18. ភាពឯកជនផ្ទាល់ខ្លួន ។ អ្នកមានសិទ្ធិទទួលបាននូវការពិចារណាអំពីភាពឯកជនរបស់អ្នក ភាពជាបុគ្គល និងអត្តសញ្ញាណនៃវប្បធម៌ ដែលទាក់ទងនឹងសង្គម សាសនា និងផ្លូវចិត្តរបស់**

អ្នក ។ បុគ្គលិករបស់មណ្ឌលត្រូវគោះទ្វារ ឬត្រូវមានការអនុញ្ញាតពីអ្នក មុនពេលចូលក្នុងបន្ទប់ លើកលែងតែក្នុងការណីសង្គ្រោះបន្ទាន់ ឬករណីដែលមើលមិនច្បាស់ ។

**19. សិទ្ធិក្នុងការទទួល** ។ អ្នកមានសិទ្ធិក្នុងការទទួលនៅមុនពេល ឬខណៈពេលទទួលឲ្យចូល ដោយផ្ទាល់មាត់ និង លាយលក្ខណ៍អក្សរជាភាសា ដែលអ្នកអាចយល់បាននូវសេចក្តីប្រកាស អំពីសិទ្ធិរបស់អ្នក និងអំពីវិធានទាំងឡាយដែលត្រូវគ្រប់គ្រងលើសកម្មភាពរបស់អ្នកក្នុង មណ្ឌល ។ អ្នកត្រូវទទួលស្គាល់ជាលាយលក្ខណ៍អក្សរក្នុងការទទួលយកព័ត៌មាននេះ និងរាល់ ការកែប្រែទាំងឡាយ ។

**20. ព័ត៌មានអំពីសុខភាពសង្គម និងការធានារ៉ាប់រងសុខភាព ។** នៅពេលទទួលឲ្យចូលក្នុង មណ្ឌល ឬនៅពេលអ្នកបានក្លាយជាអ្នកមានសិទ្ធិសម្រាប់គម្រោងសុខភាពសង្គម អ្នកមាន សិទ្ធិទទួលសេចក្តីប្រកាសស្តីពីសម្ភារៈ និងសេវាកម្ម ដែលត្រូវបានបញ្ចូលក្នុងសេវាថែទាំក្នុង មណ្ឌល ក្នុងផែនការរដ្ឋ (ដែលអ្នកមិនត្រូវគិតថ្លៃសេវាកម្មទេ) ហើយសម្ភារៈនិងសេវាកម្មដែល មាន (និងតម្លៃសេវាកម្ម) ដែលអ្នកនឹងត្រូវគិតថ្លៃ រួមទាំងថ្លៃសេវាកម្ម ដែលមិនស្ថិតនៅក្រោម គម្រោងធានារ៉ាប់រងសុខភាព ឬអត្រាកំណត់ របស់មណ្ឌល ។ អ្នកមានសិទ្ធិទទួលបានព័ត៌ មានដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរអំពីរបៀបស្នើសុំ និងប្រើប្រាស់អត្ថប្រយោជន៍ នៃគម្រោងធានារ៉ាប់រងសុខភាព និងសុខភាពសង្គម រួមទាំងសិទ្ធិធ្វើសំណើឲ្យស្រុកកំណត់ថា តើទ្រព្យសម្បត្តិរបស់អ្នកចំនួនប៉ុន្មានអាចប៉ះពាល់សិទ្ធិសម្រាប់គម្រោង សុខភាពសង្គម និង អំពីរបៀបទទួលបានមូលនិធិ ឡើងវិញសម្រាប់ការចំណាយលើកមុន ដែលត្រូវបាន គ្របដណ្តប់ដោយអត្ថប្រយោជន៍នេះ ។ **អ្នកមានសិទ្ធិបានជំនួយពីបុគ្គលិកមណ្ឌលក្នុងការ ទទួលបានព័ត៌មានទាក់ទងនឹងថាតើគម្រោងធានារ៉ាប់រងសុខភាព ឬសុខភាពសង្គម នឹងចេញ ចំណាយ សម្រាប់សេវាកម្មទាំងនេះឬទេ?**

ទាំងអ្នក និងគណនីមូលនិធិរបស់អ្នកមិនអាចត្រូវ បានគិតថ្លៃសម្រាប់សេវាកម្ម ដែលត្រូវចេញ ចំណាយដោយគម្រោងធានារ៉ាប់រងសុខភាព និងសុខភាពសង្គមទេ ។ សេវាកម្មទាំងនេះ រួមមាន សេវាថែទាំ សេវាផ្តល់អាហារប្រចាំថ្ងៃ កម្មវិធីសកម្មភាពនានាការថែទាំផ្ទះ និង សេវាថែទាំផ្សេងៗដែលទាក់ទងនឹង សេវាសង្គម និងសេវា ឬសម្ភារៈអនាម័យផ្ទាល់ខ្លួន ដែល ជាតម្រូវការរបស់អ្នក ។

"សម្ភារៈ និងសេវាអនាម័យផ្ទាល់ខ្លួន" រួមមានៈ

- សម្ភារៈអនាម័យសក់ ដូចជាក្រាស ច្រាសឡាមកោរ និងក្រែមកោរ
- សាប៊ូងូតទឹក និងសាប៊ូសម្លាប់មេរោគ ឬភ្នាក់ងារសម្អាតពិសេស នៅពេលមានការណែនាំឲ្យព្យាបាលបញ្ហាស្បែកពិសេស ឬកម្ចាត់មេរោគ
- ច្រាសដុះធ្មេញ ថ្នាំដុះធ្មេញ ក្រាសធ្មេញពាក់ បង់ស្អិត វត្ថុសម្អាតក្រាសធ្មេញពាក់ និងខាត់ធ្មេញ
- ឡេលាបស្បែក
- ជាលិកា បាល់កប្បាស សំឡីលាងដំបៅ
- ដេអូដូរ៉ង់
- ការថែទាំ និងផ្គត់ផ្គង់មើលរោគសញ្ញា ការសម្អាតអនាម័យ និងការផ្គត់ផ្គងពាក់ព័ន្ធ
- កន្សែង កន្សែងជូតមុខ និងអាវពាក់ក្នុងមន្ទីរពេទ្យ
- ថ្នាំប្រឆាំងផ្សេងៗ
- សេវាអនាម័យសក់ និងក្រចក
- ការងូតទឹក និង
- ការបោកគក់ផ្ទាល់ខ្លួន ។

អ្នកអាចនឹងត្រូវគិតថ្លៃសេវាសម្រាប់សម្ភារៈ និងសេវាកម្ម ដែលមិនស្ថិតនៅក្រោមការចំណាយរបស់គម្រោងសុភាពសង្គម និងធានារ៉ាប់រងសុខភាព រួមមានៈ

- ទូរស័ព្ទ ទូរទស្សន៍ ឬវិទ្យុមួយ ក្នុងបន្ទប់របស់អ្នក
- សម្ភារៈ ផ្ទាល់ខ្លួនដែលមានជាសុខភាពមានដូចជា ឧបករណ៍សម្រាប់ជក់ថ្នាំ និងសម្ភារៈលំហែរ និងស្ករ ឬនំផ្សេងៗ
- គ្រឿងសម្អាង និងសម្ភារៈ និងសេវាតុបតែង ដែលត្រូវស្ថិតក្រោមការចំណាយនៃគម្រោងសុខភាពសង្គម ឬធានារ៉ាប់រងសុខភាព
- សម្លៀកបំពាក់ផ្ទាល់ខ្លួន
- បញ្ហាការអានដោយផ្ទាល់ខ្លួន
- កាដូ ផ្កា និងរុក្ខជាតិ
- ព្រឹត្តិការណ៍សង្គម និងការកំសាន្ត ដែលផ្តល់ឲ្យក្រៅពីវិសាលភាពនៃកម្មវិធីសកម្មភាពនានា

- សេវាថែទាំពិសេសដែលមិនស្ថិតក្រោមការផ្តល់ឲ្យមាន ដូចជា ការជួលគិលានុបដ្ឋាយិកា ឬជំនួយការឯកជន
- បន្ទប់ស្នាក់នៅឯកជន លើកលែងតែករណីតម្រូវឲ្យសង្គ្រោះបន្ទាន់ (ឧទាហរណ៍ដាក់ក្នុងស្ថានភាពឯការដើម្បីគ្រប់គ្រងការឆ្លងមេរោគ) និង
- ការរៀបចំអាហារពិសេស ឬប្តូរមុខអាហារតាមការស្នើសុំជំនួសឲ្យអាហារដែលរៀបចំជាទូទៅដោយមណ្ឌល

**21. សេចក្តីជូនដំណឹងអំពីការបាត់បង់សិទ្ធិក្នុងគម្រោងសុខភាពសង្គម** ។ បើអ្នកទទួលអត្ថប្រយោជន៍ពីគម្រោងសុខភាពសង្គម នោះមណ្ឌលត្រូវជូនដំណឹងដល់អ្នក នៅពេលចំនួនទឹកប្រាក់ក្នុងគណនីរបស់អ្នកឡើងដល់ $200 តិចជាង ធនធាន SSI ដែលកម្រិតសម្រាប់បុគ្គលម្នាក់ៗ ហើយបើចំនួនក្នុងគណនី បន្ថែមទៅលើតម្លៃនៃធនធានមិនត្រូវលើកលែងរបស់អ្នក ឈានដល់ការកម្រិតធនធាន SSI សម្រាប់បុគ្គលម្នាក់ទេ អ្នកអាចបាត់បង់សិទ្ធិក្នុងគម្រោងសុខភាពសង្គម ឬSSI។

**22. មូលនិធិផ្ទាល់ខ្លួន** ។ អ្នកមានសិទ្ធិគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុរបស់អ្នក ហើយប្រហែលមិនតម្រូវឲ្យអ្នកដាក់មូលនិធិចូលក្នុងមណ្ឌលទេ ។ តាមការអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់អ្នក អ្នកមានសិទ្ធិដកមូលនិធិរបស់អ្នក (បើអ្នកបានដាក់ប្រាក់រក្សាសុវត្ថិភាពជាមួយមណ្ឌល) និងក្នុងគណនីដោយឡែក ។ មូលនិធិផ្ទាល់ខ្លួនដែលលើសចំនួន $50 ត្រូវបញ្ចូលបន្ថែមដោយមណ្ឌលជាការប្រាក់ដល់គណនីដោយឡែកពីគណនីប្រតិបត្តិការរបស់មណ្ឌល ហើយការប្រាក់ដែលទទួលបានត្រូវផ្តល់ចូលក្នុងគណនីរបស់អ្នក ។ មណ្ឌលអាចរក្សាមូលនិធិផ្ទាល់របស់អ្នកដែលមិនលើសពី $50 ក្នុងគណនីដែលគ្មានការប្រាក់ មូលនិធិមានសាច់ប្រាក់តិចតួច ឬគណនីមានការប្រាក់ ។ របាយការណ៍ហិរញ្ញវត្ថុរបស់អ្នកត្រូវផ្តល់ឲ្យតាមសំណើរបស់អ្នក **តែតំណាងផ្លូវច្បាប់របស់អ្នក ប៉ុន្តែរបាយការណ៍អាចត្រូវបានផ្តល់ឲ្យយ៉ាងហោចណាស់ក្នុងរយៈពេលមួយត្រីមាស** ។ បើអ្នកទទួលមរណៈភាព មូលនិធិ និងគណនីរបស់អ្នកត្រូវផ្ញើទៅបុគ្គល ឬនីតិបុគ្គលគ្រប់ទ្រព្យសម្បត្តិរបស់អ្នក ក្នុងរយៈពេល 30 ថ្ងៃ ។

**23. ការស្រាវជ្រាវពិសោធ** ។ អ្នកមានសិទ្ធិក្នុងការបដិសេធមិនចូលរួម ក្នុងការស្រាវជ្រាវពិសោធ ។

**24. ការផ្លាស់ប្តូរបន្ទប់ ឬអ្នករួមបន្ទប់** ។ អ្នកមានសិទ្ធិត្រូវបានជូនដំណឹងជាមុននៅពេលប្តូរបន្ទប់ ឬ ប្តូរអ្នករួមបន្ទប់ ។ **បើបន្ទប់របស់អ្នកត្រូវប្តូរ អ្នកត្រូវបានជូនដំណឹងជាលាយលក្ខណ៍ជាមុន 7 ថ្ងៃ ។** អ្នកមិនតម្រូវឲ្យប្តូរបន្ទប់ដើម្បីជាថ្នូរឲ្យអ្នក ឬអ្នកផ្សេងទៀតទទួលបានអត្ថប្រយោជន៍ ពីកម្មវិធីថែទាំធានារ៉ាប់រងសង្គមឡើយ ។

**25. ភាពសម្ងាត់នៃរបាយការណ៍** ។ អ្នកមានសិទ្ធិ ភាពឯកជន និងរក្សាការសម្ងាត់លើរបាយការផ្ទាល់ខ្លួន និងព្យាបាល ។ អ្នកអាចយល់ព្រម ឬបដិសេធផ្តល់ឲ្យនូវរបាយការណ៍ព្យាបាល និងផ្ទាល់ខ្លួនទៅបុគ្គលណាម្នាក់នៅក្រៅមណ្ឌល ដរាបណាអ្នកត្រូវបានផ្ទេរទៅស្ថាប័នថែរក្សាសុខភាពផ្សេង ឬការបង្ហាញរបាយការណ៍ត្រូវបានកំណត់ដោយច្បាប់ ឬកិច្ចសន្យាជាមួយតតិយជន ។ **អ្នកនឹងត្រូវបានជូនដំណឹង បើមានបុគ្គលខាងក្រៅមណ្ឌលណាម្នាក់បានស្នើសុំរបាយការរបស់អ្នកហើយអ្នកអាចជ្រើសយកមនុស្សណាម្នាក់ឲ្យអមដំណើរជាមួយ ប្រសិនបើរបាយការណ៍ ឬព័ត៌មាននោះ តម្រូវឲ្យធ្វើបទសម្ភាសជាមួយទាក់ទងនឹងបញ្ហាផ្ទាល់ខ្លួន ។**

**26. ការតវ៉ា** ។ អ្នកមានសិទ្ធិធ្វើការតវ៉ា និងការខិតខំប្រឹងប្រែង ដោយមណ្ឌលដើម្បីដោះស្រាយការតវ៉ារបស់អ្នកស្របតាមនីតិវិធីនៃការដោះស្រាយការតវ៉ារបស់អ្នកជាលាយលក្ខណ៍អក្សរ ។ **អ្នកអាចតវ៉ា និងផ្លាស់ប្តូរយោបល់ដោយសេរី ដោយគ្មានការកម្រិតព្រំដែន ការជ្រៀតជ្រែក ការគម្រាមគំហែង ការរើសអើង ឬការសងសឹក រួមមានការគម្រាមបណ្តេញចេញពីមណ្ឌល។**

អ្នកក៏មានសិទ្ធិដាក់ពាក្យបណ្តឹងទៅកាន់ការិយាល័យ ទទួលពាក្យបណ្តឹងសុខភាពនៃក្រសួងសុខាភិបាលនៃរដ្ឋ Minnesota ឬមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីការថែទាំរយៈពេលវែង ។ អាសយដ្ឋាន និងលេខទូរស័ព្ទមានបង្ហាញនៅខាងក្រោម បញ្ចប់នៃឯកសារនេះ ។

**27. សេវាកម្មឆ្លើយតប ។ អ្នកមានសិទ្ធិទទួលបានការឆ្លើយតបយ៉ាងទៀងទាត់ និងសមហេតុផលចំពោះសំណួរ និងសំណើររបស់អ្នក ។**

**28. ការពិនិត្យមើលលទ្ធផលនៃការស្ទង់មតិ** ។ អ្នកមានសិទ្ធិពិនិត្យមើលលទ្ធផលនៃការស្ទង់មតិថ្មីបំផុត**អំពីមណ្ឌលព្យាបាលដែលត្រូវបានអនុវត្តដោយអ្នកស្ទង់មតិនៃរដ្ឋសហព័ន្ធ ឬរដ្ឋ ឬអាជ្ញាធរសុខភាពមូលដ្ឋាន** និងគម្រោងកែតម្រូវណាមួយដែលមានឥទ្ធិពលទាក់ទងនឹងមណ្ឌល ដើម្បីទទួលព័ត៌មានពីភ្នាក់ងារ និងដើម្បីអាចទាក់ទងនឹងភ្នាក់ងារទាំងនេះបាន ។

**29. ការបំពេញការងារ** ។ អ្នកមានសិទ្ធិបដិសេធក្នុងការបំពេញការងារឲ្យមណ្ឌល ។

**30. សំបុត្រ ។** អ្នកមានសិទ្ធិធ្វើការទំនាក់ទំនងជាឯកជនរួមមាន ការផ្ញើ និងការទទួលសំបុត្រយ៉ាងទៀងទាត់ដែលគ្មានការបើកមើល ហើយមានសិទ្ធិចូលប្រើប្រាស់សម្ភារៈការិយាល័យ តែម និងការសរសេរផ្សេងៗដោយការចំណាយផ្ទាល់ខ្លួន ។

**31. សិទ្ធិក្នុងការចូលប្រើប្រាស់ និងមើលការទំនាក់ទំនង ។** អ្នកមានសិទ្ធិចូលប្រើប្រាស់ និងធ្វើការទំនាក់ទំនងជាមួយបុគ្គលខាងក្រោមជាលក្ខណៈឯកជនភ្លាមៗ៖

- អ្នកតំណាងរបស់រដ្ឋាភិបាល
- គ្រូពេទ្យព្យាបាលរបស់អ្នក
- មជ្ឈមណ្ឌលថែទាំប្រជាពលរដ្ឋ សម្រាប់រយៈវែង និងសេវាកម្មតស៊ូមតិ និងការសិទ្ធិផ្សេងទៀត
- ភ្នាក់ងារដែលទទួលបន្ទុកប្រព័ន្ធការពារ និងតស៊ូមតិសម្រាប់បុគ្គលដែលមានជម្ងឺស្មារតី និងវិវត្តទៅកាន់ពិការភាព
- សាច់ញាតិផ្ទាល់របស់អ្នក ឬសាច់ញាតិផ្សេងទៀតដែលជាកម្មវត្ថុនៃសិទ្ធិរបស់អ្នកក្នុងការបដិសេធ ឬដកហូតការយល់ព្រមនៅគ្រប់ពេល និង
- បុគ្គលផ្សេងទៀតដែលមកលេងដោយមានការយល់ព្រមពីអ្នក រួមមានអ្នកតំណាងរបស់អ្នក **ភ្នាក់ងារថែទាំសុខភាព បុគ្គលដែលត្រូវបានកំណត់ជាសាច់ញាតិ និង បុគ្គលផ្សេងទៀត ដែលផ្តល់សេវាសុខភាព សង្គម ច្បាប់ ដល់អ្នកដែលជាកម្មវត្ថុនៃការរឹតត្បិតដោយសមហេតុផល** និងសិទ្ធិរបស់អ្នកក្នុងការបដិសេធ ឬដកយកការយល់ព្រមនោះវិញនៅរាល់ពេល ។

**32. ការទំនាក់ទំនងជាឯកជន ។** អ្នកមានសិទ្ធិជួប និងនិយាយជាឯកជនជាមួយបុគ្គលតាមជម្រើសរបស់អ្នក ។ **អ្នកមានសិទ្ធិចាកចេញពីមណ្ឌលតាមជម្រើសរបស់អ្នក ។**

**33. ទូរស័ព្ទ ។** អ្នកមានសិទ្ធិប្រើប្រាស់ទូរស័ព្ទជាលក្ខណៈឯកជនយ៉ាងទៀតទាត់ កុំឲ្យតែការហៅរបស់អ្នក មានសម្លេងឮខ្លាំងៗពេក ។

**34. ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ។** អ្នកមានសិទ្ធិទុក និងប្រើប្រាស់ទ្រព្យសម្បត្តិផ្ទាល់របស់អ្នក រួមមានគ្រឿងតុបតែងខ្លះ និងសម្លៀកបំពាក់សមរម្យតាមកន្លែងដែលអនុញ្ញាតឲ្យ បើមិន

ដូច្នេះទេ នោះវានឹងបំពានសិទ្ធិសុខភាព និងសុវត្ថិភាពរបស់អ្នកដទៃ ។ **មណ្ឌលត្រូវរក្សាទុកកូនសោទូរសម្រាប់ទុកសម្ភារៈរូម ឬក៏ផ្តល់កូនសោទៅឲ្យបុគ្គលម្នាក់ៗ នៃកន្លែងផ្ទុកសម្ភារៈដែលអ្នកអាចទុកវត្ថុមានតម្លៃរបស់អ្នកនៅទីនោះបាន ។** មណ្ឌលទទួលខុសត្រូវសម្រាប់វិធានការការពារសមស្រប ដូចជាប្រឹក្សាយោបល់ជាមួយអ្នក និងសមាជិក គ្រួសាររបស់អ្នកអំពីហានិភ័យដែលអាចកើតមានចំពោះការនាំវត្ថុមានតម្លៃចូលក្នុងមណ្ឌល បិទស្លាកលើទ្រព្យរបស់អ្នក ទ្វារទូរត្រូវមានសោរចាក់ត្រឹមត្រូវ និងការស៊ើបអង្កេតនៅពេលមានឧបទ្ទវហេតុ ឬបាក់បែក ។ **មណ្ឌលអាច ប៉ុន្តែមិនជាប់លក្ខខណ្ឌទេ ផ្តល់ការសងជម្ងឺចិត្តបើមានការបាត់ ឬត្រូវចោរលួច ។**

**35. អ្នកស្នាក់ក្នុងមន្ទីរព្យាបាលមនុស្សចាស់ដែលបានរៀបការហើយ ។** អ្នកមានសិទ្ធិក្នុងការរំលែកបន្ទប់ស្នាក់នៅជាមួយ សហព័ទ្ធរបស់អ្នក បើសហព័ទ្ធរបស់អ្នកយល់ព្រម។ **បើអ្នករៀបការរួចហើយ អ្នកមានសិទ្ធិជួបសហព័ទ្ធរបស់អ្នកជាលក្ខណៈឯកជន។**

## ឥរិយាបថរបស់អ្នកស្នាក់នៅ និងវិធានអនុវត្តរបស់មណ្ឌល

**36. ការហាមឃាត់ ។** អ្នកមានសិទ្ធិរួចផុតពីហាមឃាត់លើរូបរាងកាយ ឬដោយប្រើសារធាតុគីមីណាមួយក្នុងគោលបំណងដាក់វិន័យ ឬក្នុងការសម្រួល និងមិនត្រូវឲ្យព្យាបាលរោគសញ្ញាអ្នកស្នាក់នៅក្នុងមណ្ឌល **លើកលែងតែត្រូវបានកត់ត្រាយ៉ាងលម្អិតថាជាការសង្គ្រោះបន្ទាន់ ឬ ត្រូវបានអនុញ្ញាតជាលាយលក្ខណ៍អក្សរ ក្រោយពីការពិនិត្យ ដោយគ្រូពេទ្យពិនិត្យព្យាបាលរបស់អ្នកសម្រាប់រយៈកំណត់ជាក់លាក់ ហើយតែក្នុងករណីដែលចាំបាច់ដើម្បីការពារអ្នកចេញពីការបង្ករបួសស្នាមដល់ខ្លួនឯង ឬអ្នកដទៃប៉ុណ្ណោះ ។**

**37. សិទ្ធិស្នើសុំ និងយល់ព្រមលើការហាមឃាត់លើរូបរាងកាយ ។** អ្នកមានសិទ្ធិស្នើឲ្យប្រើប្រាស់ការហាមឃាត់រាងកាយ ដើម្បីព្យាបាលរោគសញ្ញា ។ មុនពេលផ្តល់ឲ្យតាមសំណើរបស់អ្នក មណ្ឌលត្រូវពន្យល់អ្នកអំពីហានិភ័យទាក់ទងនឹងការផ្លាស់ប្តូរការព្យាបាលនេះ ។ គ្រូពេទ្យព្យាបាលអ្នក ត្រូវចេញបញ្ជាហាមឃាត់ ដោយកំណត់នូវរោគសញ្ញា និងកាលៈទេសៈជាក់លាក់ ដែលការហាមឃាត់ត្រូវបានយកមកប្រើប្រាស់ ។ រោគសញ្ញាព្យាបាលអាចបញ្ចូលទាំងការបារម្ភចំពោះសុវត្ថិភាពរាងកាយអ្នក តម្រូវការផ្នែករាងកាយ ឬចិត្តគំនិត ឬការភ័យខ្លាចនៃការធ្លាក់ចុះ។ មណ្ឌលនឹងតាមដានពិនិត្យមើលការប្រើប្រាស់នៃការហាមឃាត់លើរាងកាយដើម្បីការពារសុខភាព និង សុវត្ថិភាពរបស់អ្នក។ ដោយប្រឹក្សាយោបល់ជាមួយអ្នក គ្រួសារ

របស់អ្នក និងគ្រូពេទ្យព្យាបាលអ្នក មណ្ឌលនឹងវាយតម្លៃឡើងវិញជាទៀងទាត់នូវតម្រូវការរបស់អ្នកសម្រាប់ការហាមឃាត់នោះ ។ អ្នកត្រូវចុះហត្ថលេខាលើទម្រង់យល់ព្រមការហាមឃាត់នេះ ។ បើអ្នកអាចមានលទ្ធភាពក្នុងការធ្វើការសម្រេចចិត្តលើការថែទាំសុខភាពអ្នកនោះ គឺមានតែអ្នកប៉ុណ្ណោះអាចស្នើ និងយល់ព្រមលើការហាមឃាត់នេះ។ បើអ្នកមិនអាចធ្វើកើតទេ សមាជិកគ្រួសាររបស់អ្នក អាណាព្យាបាល អ្នកថែទាំ ឬភ្នាក់ងារថែទាំសុខភាព អាចស្នើសុំ និងយល់ព្រមលើកការប្រើការហាមឃាត់នេះបាន ។ [បើអ្នកចង់បានច្បាប់ថតចម្លងនៃច្បាប់រដ្ឋដែលផ្តល់នូវសិទ្ធិនេះ វាគឺជាសិទ្ធិដែលមានក្នុងច្បាប់សិទ្ធិមូលដ្ឋានរបស់អ្នកស្នាក់នៅក្នុង **មណ្ឌល នៃរដ្ឋ Minnesota** ដែលអាចរកបាននៅក្នុងមណ្ឌលរបស់អ្នក ។ បុគ្គលិក អាចប្រាប់អ្នកថាគួរទៅរកនៅទីកន្លែងណា ។]

**38. ការរំលោភបំពាន ។** អ្នកមានសិទ្ធិមិនត្រូវបានរំលោភបំពាន ទោះតាមពាក្យសម្តី ផ្លូវភេទ រាងកាយ ឬស្មារតី ការដាក់ទណ្ឌកម្មរាងកាយ និងការដាក់នៅឯការដោយមិនស្ម័គ្រចិត្ត **រួមមានការធ្វើទុក្ខបុកម្នេញ ដូចមានកំណត់ក្នុងច្បាប់ស្តីពីការការពារជនងាយរងគ្រោះ ។**

**39. បុគ្គលិកព្យាបាលអ្នកស្នាក់នៅក្នុងមន្ទីរព្យាបាលមនុស្សចាស់** ។ អ្នកមានសិទ្ធិក្នុងការបំពានជាយថាហេតុ ឬការធ្វេសប្រហែស ឬបង្ករបួសស្នាម ក្រោយការស៊ើបអង្កេតមិនដឹងហេតុ និងត្រូវចាត់វិធានការកែតម្រូវដោយសមស្រប ។ អ្នកក៏មានសិទ្ធិដាក់ពាក្យបណ្តឹងទៅភ្នាក់ងារដូចបានរៀបរាប់ខាងចុងនៃឯកសារនេះ ។

## សិទ្ធិទទួលឲ្យចូល ផ្ទេរ និងបណ្តេញចេញ

**40. ការផ្ទេរ និងការបណ្តេញចេញ** ។ អ្នកមានសិទ្ធិនៅបន្តក្នុងមណ្ឌលនិងមានសិទ្ធិបដិសេធការផ្ទេរ ឬបណ្តេញចេញ លើកលែងតែ៖

1. ការផ្ទេរ ឬការបណ្តេញចេញគឺចាំបាច់ សម្រាប់សុខភាព និងតម្រូវការរបស់អ្នក ដែលក្នុងមណ្ឌលពុំអាចផ្តល់ឲ្យបាន
2. ការផ្ទេរ ឬបណ្តេញចេញគឺសមស្របពីព្រោះ សុខភាពរបស់អ្នកបានប្រសើរឡើងយ៉ាងគ្រប់គ្រាន់ ដូច្នេះអ្នកមិនត្រូវការសេវាកម្មរបស់មណ្ឌលទៀតទេ
3. សុវត្ថិភាពរបស់បុគ្គលនៅក្នុងមណ្ឌលគឺគ្រោះថ្នាក់
4. សុខភាពរបស់បុគ្គលដែលស្នាក់នៅក្នុងមណ្ឌលអាចនឹងមានគ្រោះថ្នាក់

5. បន្ទាប់ពីមានការជូនដំណឹងសមហេតុផល និងសមស្រប អ្នកខកខានចំណាយសម្រាប់ (ឬត្រូវចំណាយក្នុងគម្រោងធានារ៉ាប់រងសុខភាព និងសុខភាពសង្គម) ការស្នាក់នៅក្នុងមណ្ឌល ឬ
6. មណ្ឌលឈប់ប្រតិបត្តិការ ។

នៅពេលដែលមណ្ឌលផ្ទេរ ឬបណ្ដេញអ្នកចេញស្របតាមកាលៈទេសៈកំណត់ពី (1) ដល់ (5) របាយការណ៍សុខភាពរបស់អ្នកត្រូវយកជាភស្តុតាង ។ ការចងក្រងជាឯកសារត្រូវរៀបចំឡើងដោយគ្រូពេទ្យរបស់អ្នក នៅពេលដែលការផ្ទេរ ឬបណ្ដេញចេញគឺជាការចាំបាច់ ស្របតាម (1) ឬ (2) ហើយដោយគ្រូពេទ្យណាក៏បាន បើការផ្ទេរ ឬបណ្ដេញចេញនោះជាការចាំបាច់ស្របតាម (4) ។

មុនពេលមណ្ឌលផ្ទេរ ឬបណ្ដេញអ្នកចេញ មណ្ឌលត្រូវ ជូនដំណឹងឲ្យអ្នក ហើយបើបានដឹង ត្រូវជូនដំណឹងដល់ សមាជិកគ្រួសារ ឬអ្នកតំណាងតាមផ្លូវច្បាប់អំពីការផ្ទេរឬបណ្ដេញចេញ និងហេតុផល ត្រូវកត់ត្រាហេតុផលក្នុងរបាយការណ៍សុខភាពរបស់អ្នក ហើយត្រូវបញ្ចូលក្នុងសេចក្ដីជូនដំណឹង៖

(a) ការបរិច្ឆេទនៃការផ្ទេរ បណ្ដេញចេញ
(b) ទីកន្លែងដែលអ្នកត្រូវបញ្ជូនទៅ
(c) ឈ្មោះអាសយដ្ឋាន និងលេខទូរស័ព្ទនៃរដ្ឋ**និងតំបន់** មជ្ឈមណ្ឌលប្រជាពលរដ្ឋសម្រាប់ការថែទាំរយៈពេលវែង
(d) បើពិការភាពរបស់អ្នកកាន់តែធ្ងន់ធ្ងរទៅ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់ភ្នាក់ងារទទួលខុសត្រូវចំពោះការការពារ និងការតស៊ូមតិរបស់បុគ្គលដែលពិការភាពចេះតែវិវត្តទៅ
(e) បើអ្នកមានជម្ងឺផ្នែកស្មារតី អាសយដ្ឋាន និងលេខទូរស័ព្ទនៃភ្នាក់ងារទទួលបន្ទុកសម្រាប់ការការពារ និងការតស៊ូមតិនៃបុគ្គលដែលមានជម្ងឺផ្នែកស្មារតី
(f) ឈ្មោះ និងអាសយដ្ឋាននៃភ្នាក់ងាររដ្ឋដែលទទួលបន្ទុកសម្រាប់ការសម្រេចលើបណ្ដឹងតវ៉ាអំពីការផ្ទេរ ឬបណ្ដេញចេញ; **និង**
**(g) សេចក្ដីប្រកាសដែលកំណត់ថា អ្នកមានសិទ្ធិជំទាស់ ឬតវ៉ាចំពោះការផ្ទេរ ឬការបណ្ដេញចេញ ។**

សេចក្តីជូនដំណឹងអំពីការផ្ទេរ ឬការបណ្តេញចេញអាចត្រូវបានធ្វើឡើង ភ្លាមៗតាមការអនុវត្តន៍ នៅពេលដែលការផ្ទេរ ឬ ការបណ្តេញចេញសម្រាប់ហេតុផល (1) ដល់ (4) ខាងលើ ឬអ្នកមិនស្នាក់នៅក្នុងមណ្ឌល សម្រាប់រយៈពេល 30 ថ្ងៃ ។ ក្នុងស្ថានភាពផ្សេងទៀត សេចក្តីជូនដំណឹងត្រូវធ្វើយ៉ាងតិច 30 ថ្ងៃមុនពេល អ្នកត្រូវបណ្តេញចេញ ឬផ្ទេរចេញ ។ **អ្នកអាចសម្រេចរើចេញមុនពេលរយៈពេលជូនដំណឹងបានផុត ។ ប្រសិនបើមណ្ឌលចង់ប្តូរអ្នកទៅបន្ទប់មួយទៀត នោះគេត្រូវជូនដំណឹងឲ្យអ្នកយ៉ាងតិច 7 ថ្ងៃមុន ។ រយៈពេលនៃការជូនដំណឹងអាចខ្លីជាងនេះ សម្រាប់ស្ថានភាពនៅក្រៅការគ្រប់គ្រងរបស់មណ្ឌល ដូចជាការស្នាក់នៅរបស់អ្នកជម្ងឺដែលទើបទទួលថ្មី ឬការផ្លាស់ប្តូរកម្មវិធីព្យាបាល ឬឱសថរបស់អ្នក ។ មណ្ឌលត្រូវតម្រូវឲ្យខំប្រឹងប្រែងដោយសមហេតុផលមួយ ក្នុងការផ្តល់ទីកន្លែងស្នាក់នៅដល់អ្នកជម្ងឺថ្មី ដោយមិនត្រូវរំខានដល់បន្ទប់ផ្សេងឡើយ ។**

អ្នកមានសិទ្ធិក្នុងការរៀបចំ និងកំណត់ទិសដៅឲ្យបានគ្រប់គ្រាន់ ដើម្បីធានាឲ្យថាការផ្ទេរ ឬការបណ្តេញចេញពីមណ្ឌលប្រព្រឹត្តិទៅដោយសុវត្ថិភាព និងរលូន ។

**41. សេចក្តីជូនដំណឹងអំពីគោលនយោបាលកាន់កាប់គ្រែ និងការទទួលយកជាថ្មីឡើងវិញ ។** បើអ្នកត្រូវផ្ទេរទៅមន្ទីរពេទ្យ ឬបន្តអវត្តមាន ពីការព្យាបាលជម្ងឺ អ្នកមានសិទ្ធិត្រឡប់មកមណ្ឌលវិញ តាមគោលនយោបាយកាន់កាប់គ្រែនៃគម្រោងសុខភាពសង្គមរបស់រដ្ឋ ប្រសិនបើអ្នកមានគម្រោងនេះ ហើយស្ថិតក្រោមគោលនយោបាយរបស់មណ្ឌលទាក់ទងនឹងរយៈពេលនៃការកាន់កាប់គ្រែ បើអ្នកមានគម្រោងសុខភាពសង្គម ។ មណ្ឌលគួរផ្តល់ឲ្យអ្នកនូវឯកសារថតចម្លងគោលនយោបាយនេះ នៅពេលដែលអ្នកត្រូវផ្ទេរ ឬបន្តអវត្តមានពីការព្យាបាលជម្ងឺ ។

ការថែទាំមណ្ឌលត្រូវបង្កើត និងអនុវត្តតាមគោលនយោបាយជាលាយលក្ខណ៍អក្សរ ដែលអ្នកនឹងត្រូវទទួលយកឡើងវិញឲ្យទៅនៅបន្ទប់ដំបូង ដែលជាបន្ទប់ពាក់កណ្តាលឯកជន បើអ្នកតម្រូវឲ្យមានសេវាកម្មរបស់មណ្ឌល ហើយអ្នកជាមានសិទ្ធិលើគម្រោងសុខភាពសង្គម ហើយការសម្រាកពេទ្យ ឬការព្យាបាលជម្ងឺរបស់អ្នកលើសលុប ផ្អែកតាមគម្រោងរបស់រដ្ឋ ។

**42. ការទទួលបានការថែទាំគុណភាពស្មើគ្នា ។** មណ្ឌលត្រូវបង្កើត និងរក្សាទុកនូវសញ្ញាណនយោបាយ និងការអនុវត្តទាក់ទងនឹងការផ្ទេរ ការបណ្តេញចេញ និងបញ្ញត្តិនៃសេវាកម្មក្រោមគម្រោងផែនការរបស់រដ្ឋសម្រាប់គ្រប់បុគ្គលទាំងអស់ដោយមិនគិតពីប្រភពនៃការចំណាយ

ឡើយ ។ រដ្ឋមិនតម្រូវឲ្យបន្ថែមសេវាកម្មផ្សេងទៀតក្នុងនាមអ្នកស្នាក់នៅក្នុងមណ្ឌលព្យាបាលមនុស្សចាស់ ក្រៅពីសេវាកម្មដែលបានផ្តល់ឲ្យដោយគម្រោងរបស់រដ្ឋឡើយ ។

## បុគ្គលផ្សេងទៀតដែលអាចអនុវត្តសិទ្ធិរបស់អ្នកបាន

អាណាព្យាបាល ឬអ្នកថៃទាំរបស់អ្នក ឬក្នុងរណីអវត្តមាន អាណាព្យាបាល ឬអ្នកថៃទាំ បុគ្គលដែលមានប្រយោជន៍អាចអនុវត្តសិទ្ធិទាំងនេះក្នុងនាមអ្នកបាន ។ បុគ្គលដែលមានប្រយោជន៍ក៏អាចស្វែងរកការអនុវត្តសិទ្ធិទាំងនេះក្នុងនាមអ្នក បើអ្នកមាន អាណាព្យាបាល ឬអ្នកថៃទាំ តាមរយៈភ្នាក់ងាររដ្ឋបាល ឬតាមរយៈតុលាការក្នុងស្រុក មានយុត្តាធិការ លើកករណីអាណាព្យាបាល និងអ្នកថៃទាំ ។ ការព្យួរលទ្ធផលនៃការអនុវត្ត ដំណើរការមណ្ឌលថៃទាំសុខភាពអាច អនុវត្តតាមការណែនាំរបស់អាណាព្យាបាល ឬអ្នកថៃទាំងដោយសុច្ចរិតភាព ។ ចេតនានៃច្បាប់នេះគឺថា សេរីភាព ឯកជន និងសាសនារបស់អ្នកមានដូចជាសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចដោយឯករាជ្យ និងការទទួលដឹងពីជម្រើសដែលមាន មិនត្រូវបានរំលោភបំពានឡើយ ហើយមណ្ឌលត្រូវលើកទឹកចិត្ត និងជួយឲ្យមានការយល់ដឹង និងអនុវត្ត សិទ្ធិទាំងនេះ ។

## ប្រភពនៃធនធាន

### មន្ត្រីចាត់តាំងផ្នែកអង្កេត និងទទួលបណ្តឹងផ្នែកការថែទាំដែលមានរយៈពេលយូរអង្វែង

ប្រអប់សំបុត្រលេខ 64971

ផ្លូវ Paul MN 55164-0971

(800) 657-3591 ឬ (651) 431-2555 (metro)

### ការិយាល័យទទួលបន្ទុកសម្រួលបណ្តឹង ផ្នែកសុខាភិបាល

ប្រអប់សំបុត្រលេខ 64970

ផ្លូវផូល (Paul) MN 55164-0970

(800) 369-7994 ឬ (651) 201-4201 (metro)

### ក្រសួងសុខាភិបាលនៃរដ្ឋ Minnesota
### ផ្នែកពិនិត្យតាមដានការអនុវត្ត

ប្រអប់សំបុត្រលេខ 64900

ផ្លូវផូល (Paul) MN 55164-0900 (651) 201-4201

### គម្រោងតស៊ូមតិដែលអភិវឌ្ឍពិការភាព
### គម្រោងច្បាប់ស្តីពីសុខភាពផ្លូវចិត្ត

430 ខាងជើងផ្លូវទីមួយ បន្ទប់ 300

Minneapolis, MN 55401-1780

(800) 292-4150 ឬ (612) 332-1441 (metro)

### គណៈកម្មការនៃការអនុវត្តការព្យាបាល

2829 ខាងត្បូងឈាមខាងកើតផ្លូវសាកលវិទ្យាល័យ បន្ទប់ 400

Minneapolis, MN 55414-3246 (612) 617-2130

**សេវាកម្មការត្រួតពិនិត្យការឃ្លាំងមើលឡើងវិញ និងសុចរិត**
**(ការក្លែងបន្លំ និងការបំពានធានារ៉ាប់រងសុខភាពរដ្ឋាភិបាល បញ្ហាទូរទាត់)**
**ក្រសួងសេវាធនធានមនុស្សនៃរដ្ឋ Minnesota**
ប្រអប់សំបុត្រលេខ 64982
ផ្លូវផ្ទូល (Paul) MN 55164-0982
(800) 657-3750 ឬ (651) 431-2650 (metro)
[អ្នកត្រូវ ទុកព័ត៌មាន ។]

**អត្ថបទត្រូវផ្តល់ឲ្យដោយសម្ព័ន្ធនៃការថែទាំនៅផ្ទះ និងសុខភាពនៃរដ្ឋ Minnesota ។ ការបកប្រែបានទទួលហិរញ្ញវត្ថុដោយក្រសួងសុខាភិបាលនៃរដ្ឋ Minnesota ។ សម្រាប់ព័ត៌មានបន្ថែមអំពីការបកប្រែនេះ**
**សូមទាក់ទង ទៅកាន់ក្រសួងសុខាភិបាលនៃរដ្ឋ Minnesota តាមរយៈទូរស័ព្ទលេខ**
**(651) 201-3701 ។**